# ២ - ប្រពៃណីអ្នកស្រុកចេនលា

## ៦. អំពីអ្នកស្រុក

តាមទំលាប់របស់ពួកមនុស្សដែលមិនទាន់ស៊ីវិល័យ ច្រើនតែមាន រូបឆោមខ្មៅគំរឹងគំរាំង មិននិយមនៅលើកោះដែលសំបូណ៌ដោយទឹកទេ ចូលចិត្តតែនៅក្នុងភូមិដាច់ស្រយាលពីគេ។ ទំលាប់បែបនេះជាការពិតណាស់។ចំនែកស្ត្រីក្នុងវាំង រឺ ស្រុកក្នុងត្រកូលថ្កុំថ្កើងវិញមានសាច់សដូចចាន ព្រោះតែគេមិនងាយបះនឹងកំដៅថ្ងៃឡើយ។ តាមធម្មតា ទាំងស្រី ទាំងប្រុស គ្មានស្លៀកដន្តប់អ្វីក្រៅពីសំពត់មួយផ្ទាំងរុំព័ទ្ធភ្ជាប់នឹងចង្កេះនោះទេ។ គេលែងខ្លួនទុកដើមទ្រូងនៅកន្តាលវាលអែសក់បួង ជើងទទេ គ្មានស្បែកជើងឡើយ ទោះជាស្រុកមហេសីស្តេចក៏ដោយ

ព្រះមហាក្សត្រមានមហេសីប្រាំអង្គ គឺអគ្គមហេសីមួយ និងមហេសីសាមញ្ញបួនប្រចាំទិសធំទាំងបួនដែរ។ ចុះពីនោះមក ខ្ញុំលឺគេថាមានស្រីស្នំ បួនពាន់ រឺ ប្រាំពាន់នាក់ ហើយមានចែកជាជាន់ថ្នាក់ និងមិនអោយដើរចេញទៅណាផ្តេសផ្តាសឡើយ។ ខ្ញុំចូលទៅក្នុងវាំងពេលណា ក៏ឃើញស្តេចខ្មែរចេញមកជាមួយអគ្គមហេសី ហើយគង់ប្រថាប់នៅក្នុងស៊ុមមាស (១) នាល្វែងកន្តាលធំទូលាយ។ ចំនែកមន្ត្រីក្នុងវាំងវិញ នាំគ្នានៅអង្គុយក្នុងថែវព័ទ្ធជុំវិញតាមលំដាប់ថ្នាក់យសសក្តិរៀងខ្លួន ហើយនាំគ្នាលបមើលពីក្រោមស៊ុមមាសនោះមក។ ខ្ញុំបានចូលទៅឃើញម្តងគឺអោយតែនរណាមានកូនក្រមុំល្អច្បាស់ជាត្រូវគេហៅអោយនាំចូលទៅក្នុងវាំង។ ពួកស្រីនៅខាងក្រោយនេះដែលដើរច្រវាត់ចេញចូលបំរើ គេហៅថាតាំងកេលាង (ស្រីង្គារ) ។ ពួកនេះមានចំនួនមិនតិចជាងមួយពាន់ រឺពីរពាន់នាក់ទេ តែអាចយកប្តីរស់នៅជាមួយអ្នកធម្មតាបាន។ ស្រុកទាំងនេះសុទ្ធតែកោរសក់ពីលើថ្ងាសបន្តិច ហាក់ដូចជាពួកអ្នកបើកផ្លូវទឹកនៅស្រុកចិនខាងជើង ហើយគេលាបជាតិហិង្គុលនៅត្រង់ជើងសក់ក្បែរគុម្ពត្រចៀកទាំងសងខាង។ នេះហើយជាសញ្ញាសំគាល់ពួកតាំងកេលាង រឺ ជេនគលាន គឺមានតែពួកនេះហើយដែលអាចចូលក្នុងវាំងបាន អែអ្នកថយថោកពីនេះទៀតចូលទៅកាន់ផ្លូវខ្វាត់ខ្វែងខាងក្រោមប្រាសាទនោះមិនបានទេ។

១ = ល៊ុមមាសនេះហើយ ដែលយើងស្គាល់ម្តងមកហើយ ហើយយើងសន្មតថាជាបុស្បុកដែកជាទីប្រថាប់ក្នុងក្រលាព្រះកំនាល់។

ស្ត្រីអ្នកភូមិធម្មតា ក៏បួងសក់ដែរ ប៉ុន្តែគ្មានសៀតស្មៀតសក់ និង តុបតែងលំអមុខឡើយ។ នៅកដៃមានពាក់កងមាសនៅនឹងម្រាមដៃ មានពាក់ចិញ្ចៀនមាស។ ម្យ៉ាងទៀតពួកជេនគាឡាង និងអ្នកនៅក្នុងវាំងទាំងប្រុសទាំងស្រី សុទ្ធតែលាបប្រេងក្រអូបដែលផ្សំឡើងពីជាជាតិឈើក្រអូប និងក្រលៀនប្រើស។

គ្រួសារទាំងអស់សុទ្ធតែគោរពប្រតិបត្តព្រះពុទ្ធសាសនា។
ក្នុងប្រទេសនេះ មានមនុស្សស្រីភេទខ្លះស្អាតៗ រាល់ថ្ងៃតែងដើរជាក្រុមដប់នាក់ រឺ លើសពីនេះ ទៅពាសពេញទីផ្សារជាញឹកញយណាស់ មានបំនងទាក់ទងពួកចិនៗ ដូរយករបស់មានតំលៃ ដែលជាទំលាប់មួយមិនល្អ មិនថ្លៃថ្នូរសោះ។

## ៧. អំពីស្ត្រីសំរាលកូន

ស្ត្រីស្រុកនេះ ក្រោយដែលសំរាលកូនរួចទៅ គេយកបាយក្តៅប្រលាក់លាយអំបិល ហើយញាត់ចូលទៅក្នុងទ្វារមាស លុះដល់បានមួយយប់មួយថ្ងៃ ទើបគេយកចេញមកវិញ។ ការធ្វើដូច្នេះ ជាហេតុនាំអោយមិនសូវមានជំងឺ និងអោយបានរួម

ទ្វារមាសតូចដូចជាស្រ្តីក្រមុំទៀត។ កាលខ្ញុំទើបដឹងរឿងនេះដំបូង ឆ្ងល់ថា ក្រែងមិនពិតដូច្នោះទេដឹង? ព្រោះថា បើបានជាមានប្តី និងមានកូនទៅហើយចុះម្តេចខ្លាចគេដឹងរឿងនេះទៀត? ប៉ុន្តែនៅនឹងផ្ទះដែលខ្ញុំសំនាក់នៅមានស្រ្តីម្នាក់សំរាលកូន ដែលជាហេតុនាំអោយខ្ញុំដឹងរឿងនេះច្បាស់លាស់ នៅក្រោយពេលសំរាលកូនហើយ មួយផ្នែកទៀត ស្រីនោះពកូនខ្ញីទៅមុជទឹកទន្លេ ដែលជាការចំលែកមិនដែលជួបប្រទះទេ។

នៅពេលដែលខ្ញុំទៅជួបគេម្តងណា គេតែងពោលថា ស្រីស្រុកនេះក្រាស់ដោយកាមតណ្ហាណាស់។ ក្រោយពេលដែលសំរាលកូនហើយមួយថ្ងៃ រឺ ពីរថ្ងៃប៉ុណ្ណោះ គេក៏រួមដំនេកជាមួយប្តីទៀតហើយ។ បើប្តីនោះបំពេញចំនង់ខ្លួនមិនបាទទេ នឹងត្រូវគេបោះបង់ចោលដូចពួកបួយឆេង(១) មិនខាន។ ប្រសិនប្តីនោះមានធុរៈទៅស្រុកឆ្ងាយអស់ច្រើនយប់ ចាប់ពីដប់យប់ឡើងទៅ ច្បាស់ជាត្រូវប្រពន្ធស្តីអោយថា ខ្ញុំមិនមែនស្រ្តីខ្មោចទេ តើអោយខ្ញុំដេកម្នាក់អែងម្តេចនឹងបាន?។ ខ្ញុំលឺថា មានស្រ្តីច្រើនណាស់រក្សាទុកសេចក្តីបរិសុទ្ធរបស់ខ្លួន។ ស្រ្តីៗច្រើនតែឆាប់ចាស់ណាស់ ពីព្រោះតែគេឆាប់មានប្តី ឆាប់មានកូនពេក។ មនុស្សដែលមានអាយុ ២០ រឺ ៣០ គឺប្រហែលគ្នានឹងជនជាតិចិនដែលមានអាយុ ៤០ រឺ ៥០ឆ្នាំដូច្នោះដែរ។
១ = បួយឆេង ប្រែថា មន្រ្តីទិញ គឺពួកដែលគេទិញដាច់ មិនអោយទៅនៅមានប្រពន្ធកូនឡើយ។

### ៨. អំពីស្រ្តីក្រមុំ

ពួកអូវពុក ម្តាយដែលមានកូនស្រី តែងអោយពរកូនថា «សូមអោយអែងទៅអនាគតបានជាស្រីដែលមានប្តីរាប់ពាន់(២)។ កូនស្រីក្នុងគ្រួសារអ្នកមានចាប់ពិអាយុ ៧ ទៅ ៩ឆ្នាំ គ្រួសារអ្នកក្រខ្សត់រហូតដល់អាយុ ១១ឆ្នាំ គេនិមន្តលោក រឺតាបសមកបើកមុខកូនស្រីហៅថា ឆិនថាន់(៣)។
២ = ពរនេះ បានន័យថា អោយមានគេស្រលាញ់ច្រើន ដូចទំលាប់ពួក កួយ-ពុង បើមានកូនក្រមុំ គេអោយដេកនៅផ្ទះបាយ ទុកអោកាសពេលយប់អោយកំលោះចូលទៅស្គាល់លលួងចុះ។ ៣ = ឆិនថាន់ នេះមិនដឹងជាពាក្យដើមថាអ្វី រកប្រែអោយជាន័យច្បាស់ពុំទាន់ឃើញ។

ពិធីនេះ រាជការដាក់កំរិតអោយធ្វើមួយឆ្នាំម្តង នៅក្នុងខែដែលត្រូវនឹងខែទី៤ របស់ចិន ដោយរើសយកថ្ងៃណាមួយធ្វើតែម្តង។ អ្នកមានកូនស្រីដែលត្រូវធ្វើពិធីនេះ តោងជំរាបរាជការជាមុន ហើយអ្នករាជការ គេក៏អោយទៀនធំមួយដើមមកទុកមុន និងមានគូសគំនូសមួយជាកំនត់សញ្ញាផង ថាដល់ពេលយប់ធ្វើពិធីនេះ បើដុតទៀនអស់ត្រឹមគន្លាក់នោះហើយត្រូវចាប់ពិធី ឆិនថាន់ ឡើង។

នៅមុនពេលដែលធ្វើពិធីនេះមួយខែ រឺ កន្លះខែ រឺ ដប់ថ្ងៃ អូវពុកម្តាយត្រូវជ្រើសរើស លោក រឺ តាបសណាមួយប្រកាន់ទុកជាមុន ទោះបីនៅវត្តណាក៏ដោយ ក៏តែងតែមានគេទៅនិមន្តដែរ។

លោកគ្រូអង្គណាដែលសំខាន់ៗជាងគេ តែងតែត្រូវពួកមន្រ្តី រឺអ្នកមានគេនិមន្តទុកអស់ហើយ អែអ្នកក្រ ពុំអាចជ្រើសរើសរកលោកបានតាមចំនង់ឡើយ។ មន្រ្តី រឺ អ្នកមាន គេបូជាលោកនូវសុរា អង្ករ កំនាត់សំពត់ ស្លាម្លូ និងគ្រឿងប្រាក់យ៉ាងច្រើនរហូតដល់ទៅ ១០០អំរែកផង ហើយមានតំលៃប្រមាណមិនតិចជាងសាច់ប្រាក់ចិន ២០០រឺ ៣០០ តំលឹងឡើយ។ អ្នកមានរបស់របរតិច ក៏គង់ ៣០ - ៤០ រឺ ១០ -២០ អំរែកដែរ។ ដូច្នេះ គ្រួសារអ្នកក្រត្រូវរង់ចាំដល់កូនស្រីអាយុ ១១ឆ្នាំ ទើបចាប់ធ្វើពិធីនេះ មកពីពិបាករករបស់របរទាំងនេះអែង។

មានអ្នកខ្លះ គេជួយលុយដល់កូនអ្នកក្រអោយធ្វើពិធីនេះដែលគេទុកជាការសាងកុសលមួយដែរ។ ក្នុងមួយឆ្នាំលោក រឺតាបសមួយអង្គអាចទទួលនិមន្ត ធ្វើពិធីនេះអោយក្មេងស្រីបានតែមួយនាក់ទេ បើលោកយល់ព្រម នឹងអ្នកណាមួយហើយមិនអាចទទួលអ្នកដទៃទៀតបានទេ។

នៅពេលយប់ដែលធ្វើពិធីនេះ គេមានរៀបចំគ្រឿងស៊ីផឹក និង ភ្លេងភ្លាត់ទ្រហឹងអឹងកង។ ក្រៅពីការជួបជុំញាតិមិត្តជិតឆ្ងាយ គេមានសង់ធ្វើជារោងមួយ តំកល់រូបមនុស្ស រូបសត្វដែលសូនធ្វើអំពីដី។ អ្នកមានយសសក្តិ ធ្វើរូបនេះដល់ទៅជាងដប់ អែអ្នកធម្មតា យ៉ាងហោចមកក៏មានបី រឺ បួនដែរ។

ចំពោះអ្នកដែលទាល់ក្រខ្លាំងវិញ គ្មានធ្វើរូបនេះទេ គិតតែរៀបពិធីតែម្តងទៅ លុះដល់ពេលគ្រប់ ៧ថ្ងៃ ទើបគេរុះរោងនេះចេញ។ នៅយប់ដែលធ្វើពិធីនោះទៀតគេយកគ្រែស្នែងទៅនិមន្តលោកហើយបាំងក្លស់ និង លេងភ្លេងដង្ហែនាំយកមក។ គេមានកូនតូបពីរដូចគ្រែស្នែងដែរ ដែលបិទបាំងលំអដោយព្រែពណ៌ភ្លឺព្រាល។ តូបមួយសំរាប់អោយកូនស្រីនោះអង្គុយអែតូបមួយទៀត សំរាប់លោក រឺ តាបសគង់សូត្រធម៌ តែខ្ញុំមិនដឹងលោកសូត្រអ្វីឡើយ។ ពេលនោះភ្លេងក៏ប្រគំ លឺ គឹកកងរំពងដែរ។ ខ្ញុំលឺថាយប់នេះគ្មានត្រនមអ្វីទេ គ្រាន់តែដឹងថា ដល់ពេលវេលាភ្លាមលោក រឺ តាបសនោះក៏ចូលទៅក្នុងបន្ទប់ជាមួយកូនស្រី ហើយលូកដៃរបស់លោកផ្ទាល់ទៅយករបស់កូនស្រីដាក់ទៅក្នុងស្រា(១)។ ខ្លះទៀតថា យកមកភ្លក្សគ្រប់គ្នា ហើយខ្លះថា លោកក៏រួមរ័កជាមួយកូនស្រីក្នុងពេលនោះ តែខ្លះថា អិតមានទេ។ រឿងនេះ គេមិនអោយពួកចិនបានឃើញផ្ទាល់ទេ ហេតុនេះ ទើបខ្ញុំមិនអាចបានដឹងនូវការពិតឡើយ។

១ = ត្រង់នេះ អត្ថបទដើមក៏និយាយមិនច្បាស់សេចក្តីដែរ យើងប្រែអោយនៅន័យត្រឹមតាមឃ្លាដើមជា (អក្សរចិន)។ ត្រង់នេះលោក ប៉េលីយោត ប្រែថា : Il lade flore avec la main et recueille ses premices dans du vin។ អ្នកបកប្រែសូមបញ្ជាក់ថា : រឿងរ៉ាវក្នុងវគ្គនេះ ពុំដែលលឺក្នុងទំនៀមខ្មែរទេ ប៉ុន្តែយើងប្រែតាមតែអត្ថបទដើមប៉ុណ្ណោះ មិនហ៊ានបំបាត់ចោលឡើយ។

លុះពេលទៀបភ្លឺទើបគេដង្ហែលោកដោយគ្រែស្នែងមានភ្លេងនឹងបាំងក្លស់ នាំយកទៅវិញ ហើយគេយករបស់ល្អៗ មានព្រែពណ៌ជាដើម ទៅធ្វើជាថ្នូរលស់យកកូនស្រីនោះមកវិញ។ បើពុំធ្វើដូច្នេះទេ កូនស្រីនេះមិនអាចយកទៅអោយមានប្តីដទៃទៀតបានឡើយ ព្រោះនៅជាកម្មសិទ្ធិរបស់លោកនៅឡើយ។

ពេលដែលខ្ញុំបានឃើញរឿងរ៉ាវនេះ គឺនៅថ្ងៃ៦ ខែទី ៤ នៃឆ្នាំតេងអីវ ក្នុងរជ្ជការស្តេច តាយតេក (គ.ស ១២៩៧)នៅពេលដែលមុនធ្វើពិធីនេះ កូនស្រីត្រូវនៅដេកក្នុងបន្ទប់ជាមួយអូវពុកម្តាយ លុះដល់ធ្វើពិធីនេះរួចហើយ កូនស្រីត្រូវបែកទៅដេកបន្ទាប់ដទៃ ហើយនាងចង់ទៅដេកកន្លែងណាក៏បាន តាមចិត្តចង់ អិតមាននរណាតាមមើលគយឃ្លាំឡើយ។

ចំពោះរឿងអាពាហ៍ពិពាហ៍វិញ ពិតមែនតែមានតំរូវអោយជូនលុយកាក់ជាច្រើន ប៉ុន្តែគេមានអនុគ្រោះច្រើនដែរ។ មានខ្លះគេអាចដេកនៅរួមរ័កនឹងគ្នាជាមុនទៅហើយទើបរៀបការជាក្រោយក៏បាន។ តាមប្រពៃណីគេមិនចាត់ទុកការណ៍នេះជាការគួរខ្មាសអៀន រឺ ចំលែកឡើយ។

នៅយប់ដែលធ្វើពិធី ឆិនថាន នោះ ជួនកាលនៅតែតាមផ្លូវមួយមានដល់ទៅដប់ផ្ទះអែនោះ រៀបធ្វើពិធីនេះ។នៅតាមទីក្រុងអ្នកណាហ៊ានដើរកាត់ហ្វូងពិធី ពីមុខលោក រឺ តាបសទាំងនេះ ច្បាស់ជាវង្វេងវង្វន់ផ្លូវហើយ ណាមួយលឺគឹកកងស័ព្ទសូរភ្លេងគ្មានចន្លោះត្រង់ណាទេ។

### ៩. អំពីទាសាទាសី

គេសុទ្ធតែទិញមនុស្សព្រៃ(១) យកមកបង្ខំអោយធ្វើជាទាសាទាសី។ អ្នកដែលមានច្រើន គឺមានទាសាទាសីដល់ទៅជាងមួយរយនាក់ អែអ្នកដែលមានតិច ក៏ត្រឹម១០ - ២០នាក់ដែរ លើកលែងតែអ្នកក្របំផុតទើបគ្មានសោះ។ចំនែកមនុស្សព្រៃទាំងនោះ គឺអ្នករស់នៅក្នុងព្រៃភ្នំ មានជាវង្សត្រកូលមួយហៅថាអាចោរ «ចុង»(២) (ជង?)។ពួកនេះបើមកនៅកន្លែងណាហើយ មិនហ៊ានចេញដើរទៅណាក្រៅផ្ទះឡើយ។ ពួកអ្នកស្រុកក្រុង គេឈ្លោះគ្នា គេជេរគ្នាថា អាចុងៗ ដូច្នេះ គេ

ខឹងខ្លាំងណាស់ ព្រោះទុកជាការមើលងាយយ៉ាងធ្ងន់។ ក្មេងៗមានកំលាំងពេញលក់បានតំលៃមួយរយ «ប៉ូវ»(៣) បើចាស់ៗខ្សោយកំលាំងបានតែ៣០ រឺ ៤០ទេ។

១ = មនុស្សព្រៃនេះ គឺពួកអ្នកស្រុកដើមដែលរស់នៅដោយព្រៃមិនទាន់មានទទួលស៊ីវិល័យ គេកៀរចាប់មកលក់
២ = លោកប៉េលីយោត ក៏សន្និដ្ឋានថា ពាក្យនេះមកពី «ជង» ដែរ ហើយអះអាងថាជាពាក្យដែលអានតាមសំលេងចិនក្នុងសតវត្សទី១៣។ ៣ = លោកប៉េលីយោត បន្ថែមន័យថា D'étoffe ពុំដឹងជាមានកំនត់ប៉ុន្មានទេ តែនេះយើងប្រែតាមពាក្យដើមថា ប៉ូវ ដែលប្រែថា កំនាត់សំពត់។

ពួកនេះ គេអោយនៅតែក្រោមផ្ទះ លុះត្រាមានការប្រើចាំបាច់ទើបគេអនុញ្ញាតអោយឡើងលើផ្ទះ ហើយត្រូវអោយលុតជង្គង់លើកដៃសំពះគេសិន ទើបអាចអោយដើរចូលក្នុងផ្ទះបាន។ គេហៅម្ចាស់គេថា ប៉ាថូ(១) ហៅម្ចាស់ស្រីថា មី(២) ។ ប្រសិនបើមានកំហុសត្រូវគេវាយដំវិញ ពួកនេះសុខចិត្តជ្រប់មុខបន្ទោយអោយគេវាយតាមចិត្ត មិនហ៊ានរើបំរះឡើយ។ ពួកនេះស្រី-ប្រុស គេយកតែគ្នាគេជាប្តី-ប្រពន្ធ គ្មានសិទ្ធិយកអ្នកដទៃឡើយ។ បើមានពួកចិនទៅនៅស្រុកនោះយូរ លួចរួមរ័កជាមួយស្ត្រីពួកនោះ ដោយការស្រេកឃ្លានកាមតណ្ហា ហើយម្ចាស់គេទាន់ នោះអ្នកផងគេលែង អោយចិននេះអែងអង្គុយជាមួយគេហើយ ព្រោះខ្លួនលួចលាក់ជាមួយពួកទាសៈ។បើពួកទាសៈទាំងនេះ ទាក់ទងលួចលាក់ជាមួយអ្នកក្រៅ រហូតដល់មានផ្ទៃពោះ កើតបានជាកូនទៅ ក៏ចៅហ្វាយនាយអិតសួររកហេតុផលឡើយ។ បានជាគេមិនសួរមកពីគេយល់ថា បើទាសៈនោះ កាលណាបានកូនមក នឹងបានផលដល់គេ ព្រោះថ្ងៃក្រោយគេនឹងចំរើនទាសៈឡើងទៀត។ បើទាសៈណាលួចរត់ ហើយគេតាមចាប់បានមកវិញ គេត្រូវយកមកសាក់មុខ ចំកន្តាលថ្ងាសពណ៌ខៀវ ជាគ្រឿងចំនាំ ហើយគេដាក់ឃ្នាងជាប់នឹងក ជួនដាក់ឃ្នាងជាប់ទាំងដៃជើងទៀតផង។

១ = ទំនងជាមកពី ប៉ាតាវ ដែលនៅសល់ក្នុងភាសាជនជាតិដើមចារ៉ាយ ហៅអូវពុក។ សំលេងចិនអានថា មី សំដៅពាក្យហៅម្តាយថា មេ។

## ១០. អំពីភាសា

ភាសាចិន មានសំលេងប្រហាក់ប្រហែល នឹងភាសាអ្នកស្រុកនេះដែរ តែនិយាយប្រស្រ័យស្តាប់គ្នាមិនបានទេ ស្រុកនេះមានភាសាមួយពិសេស ទោះបីជាភាអ្នកជិតខាងខ្លួនដូចជាចាម រឺ សៀម ក៏មិនអាចដូចគ្នាស្តាប់គ្នាបានឡើយ។ ១គេថាមួយ ២ ថាព័ត ៣ថា បេក ៤ថា ពួន ៥ថា ពុណាំ ៦ថា ពុំណាំមួយ ៧ពុណាំព័ត ៨ពុណាំបេក ៩ពុណាំពួន ១០ថាតាប់។ គេហៅ
អូវពុកថា ប៉ាថូ អូវពុកធំ អូវពុកមា ក៏ហៅប៉ាថូដែរ។ ម្តាយ គេហៅ មី អែម្តាយមីង និង ស្ត្រីអ្នកជិខាងក៏គេហៅមីដែរ។ បងស្រី ប្រុស ហៅថាប៉ង ប្អូនប្រុសស្រី ហៅថា ផូវអ៊ូង។ មាខាងម្តាយហៅថា អាកឡៃ អែប្តីរបស់ម្តាយមីងខាងអូវពុកហៅថា ពូឡៃ។ គេប្រើពាក្យយកខាងចុងជាដើមបញ្ច្រាស់គ្នា។ អុបមាដូចពាក្យ នេះមនុស្សទាសាំ ជាប្អូន គេថាផូងអ៊ូងទាសាំ ពាក្យថា នេះមនុស្ស លីស៊ីមាខាងអូវពុក គេថា ងាន ឡៃលីស៊ី អុបមាមួយទៀត ដូចគេហៅចិនថា ពីស៊ី ហៅមន្ត្រីថា ប៉ាតេង ហៅអ្នកប្រាជ្ញថា ប៉ានឃាប លុះដល់គេចង់ថាមន្ត្រីចិន រឺអ្នកប្រាជ្ញចិន គេមិនថា ពីស៊ីប៉ាតេង រឺ ពីស៊ីប៉ានឃាបទេ គេទៅជាប្រើថា ប៉ាតេងពីស៊ី រឺ ប៉ានឃាមពីស៊ី(១) ទៅវិញ។

១ = ប៉ាតេងពីស៊ី = មន្ត្រីចិន។ ប៉ានឃាបពីស៊ី = អ្នកប្រាជ្ញចិន។

ទាំងនេះ គ្រាន់តែលើកយកជាអុទាហរណ៍គោលៗទេ។ ម្យ៉ាងទៀត គឺមន្ត្រីគេនិយាយតាមបែបមន្ត្រី អ្នកប្រាជ្ញនិយាយគ្នាតាមភាសាអ្នកប្រាជ្ញ លោកសង្ឃ រឺ តាបស ក៏មានពាក្យសំដីប្រើរបៀបខ្លួនជាសង្ឃ ជាតាបស អែអ្នកស្រែចំការក៏និយាយប្លែកតាមបែបរបស់គេដែរ មិនប្លែកអ្វីពីរបៀបប្រើភាសាអ្នកស្រុកចិន។

## ១១. អំពីមនុស្សព្រៃ

មនុស្សព្រៃមានពីរបែប។ មួយពួកជាពួកចេះនិយាយភាសាអ្នកស្រុកស្តាប់គ្នាបាន គឺពួកមនុស្សព្រៃលក់ខ្លួនជាទាសៈ បំរើ

គេនេះអែង។ មួយទៀត គឺពួកមនុស្សព្រៃដែលនិយាយស្តាប់ភាសាគ្នាមិនបាន គ្មានរវល់នឹងការចំរើន។ ពួកនេះ គ្មានចេះធ្វើផ្ទះជ្រកនៅទេ តែងនាំគ្នាទាំងគ្រួៗដើររស់នៅតាមភ្នំ។ ក្បាលគេមានពាក់អ្វីម្យ៉ាងធ្វើពីដីរាងដូចឆ្នាំង។ បើដើរទៅជួបនឹងសត្វព្រៃ គេបាញ់នឹងព្រួញ រឺ ពួយនឹងលំពែង បានសត្វនោះមក ក៏គូសដុំថ្មយកភ្លើង ចំអិនសត្វ រួចអង្គុយដំកង់ចែកគ្នាស៊ី។ រួចហើយដើរទៅទៀត។ ពួកនេះកាចសាហាវណាស់ តែងសំលាប់ក្រុមជាមួយ ហើយចេះផ្សំថ្នាំពិស ពូកែសក្តិសិទ្ធណាស់។ នៅដីវាលជិតខាងកន្លែងនៅ គេមានដាំសន្តែកគួ ដើមក្រវាញ និង ដើមកប្បាស ត្បាញសំពត់ជាវិជ្ជាជីវៈ។ សំពត់របស់គេនោះ សាច់ក្រាស់គ្រើម ហើយមានពណ៌ក្រវេមក្រវាមណាស់ផង។

## ១២. អំពីអក្សរសាស្ត្រ(១)

លិខិតធម្មតា និងអត្ថបទទាំងអស់ ដូចជាអែកសារផ្លូវការជាដើម សុទ្ធតែសរសេរលើស្បែកសត្វប្រើស រមាំង រឺ ស្បែកដទៃទៀត ដែលគេយកមកហាលស្ងួតលាបពណ៌ខ្មៅ។ គេកាត់ស្បែកនោះអោយមានទំហំធំ រឺ តូច ទៅតាមសេចក្តីត្រូវការ និងយកម្សៅម្យ៉ាងមកប្រើ មានសន្ឋានដូចដីសនៅស្រុកចិន ដោយលញ់អោយវែង ចិតចុងស្រួចគេហៅថា សោ(២) ហើយគេសរសេរដោយដៃ បានជាប់ជិតល្អណាស់ មិនងាយនឹងរលុបឡើយ។ កាលណាគេសរសេរហើយ គេយកដីសនោះមកសៀតនឹងត្រចៀក នាំអោយគេចំនាំបានថា អ្នកនេះហើយជាអ្នកសរសេរ។ បើសរសេរហើយត្រូវការលុបវិញ តោងប្រើរបស់ទទឹកយកមកជូតទើបរលុបអក្សរនោះទៅវិញ។ អក្សរនេះ មានសន្ឋានដូចអក្សរជនជាតិហ្វយគូរ (តួរក៍) ដូច្នេះដែរ។ ការសរសេរជាលិខិតអ្វីក៏ដោយ គេសុទ្ធតែសរសេរពីក្រោយទៅមុខ មិនមែនសរសេរពីលើចុះក្រោម។ ខ្ញុំលឺអ៊ាសាយហាយ៉ា និយាយថាស្រះនៃអក្សររបស់គេ ស្រដៀងគ្នានឹងអក្សរជាតិមុងហ្គោលដែរ មានប្លែកគ្នាតែពីរបីប៉ុណ្ណោះ។ កាលនោះគ្មានអត្ថបទបោះពុម្ពទេ ប៉ុន្តែមានអ្នកនិពន្ធ និងអ្នកតែងកាព្យពេចន៍ដែរ។

១ = លោកប៉េលិយោត ប្រែត្រង់នេះថា Ecriture ។ តែន័យយើងថានេះទូលាយជាង ព្រោះតំរូវតាមអក្សរចិន (?) ។

២ = ត្រង់នេះលោកប៉េលិយោតថា ហៅថាសូ ទៅវិញ។ តែបើលឺតាមចាស់ៗនិយាយតៗមកថា គេសរសេរនឹងដីសពង គឺដីសុទ្ធ តែដូចម្សៅ។

Website : www.khmercenter.ch មណ្ឌលវប្បធម៌ខ្មែរនៅប្រទេសស្វីស
ជាសេវាកម្ម ក្នុងការផ្សាយពុទ្ធសាសនា វប្បធម៌ ជាភាសាខ្មែរ

Khmer Culture Center in Switzerland,
Phone (41)44 3635900 , Fax (41)44 3635900

© 2004 The Switzerland Buddhist Society, (watkhmer) Inc. All rightsreserved.